## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**នីតិរដ្ឋ ភាតរភាព វឌ្ឍនភាព**

# លក្ខន្តិកៈ

## របស់

# គណបក្សប្រជាធិបតេយ្យជឿនលឿន

By-Laws

DEMOCRATIC PROGRESSIVE PARTY

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**នីតិរដ្ឋ ភាតរភាព វឌ្ឍនភាព**

# លក្ខន្តិកៈ

**របស់**

# គណបក្សប្រជាធិបតេយ្យជឿនលឿន

By-Laws

DEMOCRATIC PROGRESSIVE PARTY

# បុព្វកថា

ដោយយល់ឃើញថា ក្រោយសម័យមហានគរ "អង្គរ" ប្រទេសកម្ពុជា និងប្រជាពលរដ្ឋខ្មែរ បានឆ្លងកាត់នូវមហាសោកនាដកម្ម ដោយសារសង្គ្រាមផ្ទៃក្នុង និងសង្គ្រាមឈ្លានពានលេបទឹកដីពីសំណាក់បរទេសឥតឈប់ឈរ ដែល បាននាំមកនូវក្តីវិនាសមហន្តរាយ ដល់ជីវិតប្រជាពលរដ្ឋ និងមាតុភូមិកម្ពុជា ស៊ឹងតែរលាយរលត់។ ដ្បិតមានកិច្ចព្រមព្រៀងអន្តរជាតិ ស្តីពីកម្ពុជា នៅហ្សឺណែវឆ្នាំ១៩៥៤ និងនៅប៉ារីស៍ឆ្នាំ១៩៩១ក្តី ក៏បញ្ហាប្រឈម និងហានិភ័យ នៅតែអាចកើតមានជាយថាហេតុ។ ហេតុនេះ កិច្ចការពារជាតិ ការពារបូរណភាពទឹកដី និងសិទ្ធិសេរីភាព ដើម្បីប្រជាពលរដ្ឋខ្មែរ ជាគោលបំណង និងជាករណីយកិច្ចចម្បងបំផុតរបស់យើងខ្ញុំ រួមជាមួយពលរដ្ឋខ្មែរគ្រប់រូប។

ដោយយល់ឃើញថា កិច្ចការពារជាតិមាតុភូមិ និងសន្តិភាព ត្រូវការជាចាំបាច់នូវការឯកភាពជាតិ និងការចូលរួម យ៉ាងសកម្មពីប្រជាពលរដ្ឋ។ ការបែកបាក់ជាតិបានកើតឡើងជាច្រើនលើក រហូតមានការផ្ទុះជាសង្គ្រាមផ្ទៃក្នុងជាតិផងដែរ។ ស្ថានភាពនៃការបែកបាក់ជាតិនេះត្រូវតែបញ្ចប់ ដោយជំនួសមកវិញនូវការផ្សះផ្សាជាតិដើម្បីបង្កើតបាននូវស្ថិរភាពផ្ទៃក្នុងជាតិ តាមរយៈការគោរព និងលើកកម្ពស់សិទ្ធិសេរីភាព យុត្តិធម៌ និងផ្តល់សេចក្តីគោរពទុកចិត្តគ្នាទៅវិញទៅមក ក្នុងគំនិតស្មារតី ប្រជាធិបតេយ្យ សេរី និងការទទួលខុសត្រូវ ស្របតាមដំណើរនៃពិភពលោកទៅកាន់យុត្តិធម៌ សមភាព និងសេរីភាព ដើម្បីសេចក្តីចម្រើនរុងរឿង និងសន្តិភាព សម្រាប់មនុស្សជាតិ។ គោលការណ៍ទាំងនេះ ត្រូវបានកំណត់រួចហើយក្នុងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងសន្តិភាព រវាងភាគីអន្តរជាតិ និងគ្រប់ភាគីខ្មែរ នាទីក្រុងប៉ារីស៍ ឆ្នាំ១៩៩១ និងក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ដែលត្រូវបានប្រជាពលរដ្ឋខ្មែរគាំទ្រ និងទទួលយកជាឯកច្ឆន្ទ ជាច្បាប់នយោបាយកំពូលនៃប្រទេសកម្ពុជា។

ដោយយល់ឃើញថា សាកលភាវូបនីយកម្ម នៃពិភពលោកនៅសម័យថ្មីនេះ ជះឥទ្ធិពលអវិជ្ជមាន និងអាចផ្តល់នូវគ្រោះថ្នាក់ជាច្រើនដល់សង្គមជាតិ បានជំរុញឱ្យយើងរួមគ្នាគិតរក្សាការពារ ឯករាជ្យ អត្តសញ្ញាណជាតិ ជីវភាព សេដ្ឋកិច្ច ទីផ្សារ របស់យើងជាចាំបាច់បំផុត ដោយរៀបចំ កសាងរដ្ឋទំនើប សង្គមជឿនលឿន មានអារ្យធម៌ថ្លៃថ្នូរ យុត្តិធម៌ សមធម៌ នីតិរដ្ឋ ប្រជាធិបតេយ្យសេរី។

ដោយការប្តេជ្ញាចិត្តដាច់ខាត បម្រើឧត្តមគតិខាងលើនេះ យើងខ្ញុំទាំងអស់គ្នាបានសម្រេចចិត្ត បង្កើតគណបក្សនយោបាយមួយ ដែលមានលក្ខណៈប្រជាធិបតេយ្យសេរី កើតចេញមកពីការប្រមូលផ្តុំអ្នកស្នេហាជាតិ និងអ្នកប្រជាធិបតេយ្យសេរី ស្របតាមឆន្ទៈរបស់ប្រជាពលរដ្ឋខ្មែរ ដែលមានឈ្មោះ និងមានគោលនយោបាយ ដូចតទៅ ៖

## ជំពូកទី១
## ឈ្មោះ សញ្ញាសម្គាល់ និងទីស្នាក់ការ

**ប្រការ ១ ( ថ្មី ) ៖**

គណបក្សនយោបាយនេះមានឈ្មោះថា «**គណបក្សកម្ពុជានិយម**» ហើយត្រូវបានដូរឈ្មោះ ក្នុងឱកាសសមាជវិសាមញ្ញ នៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៥ ជា «**គណបក្សប្រជាធិបតេយ្យជឿនលឿន**» និងអក្សរកាត់ «ប.ជ.ល» ជាអក្សរឡាតាំង «DEMOCRATIC PROGRESSIVE PARTY» និងអក្សរកាត់ «D.P»។

**ប្រការ ២ ( ថ្មី ) ៖**

គណបក្សប្រជាធិបតេយ្យជឿនលឿន មានសញ្ញាសម្គាល់ រូបពន្លឺភ្លើងមានកាំរស្មីលើជើងទម្រ នៅចំកណ្តាលចតុកោណស្មើពណ៌ខៀវ ៖

- អក្សរកាត់ **ប.ជ.ល** និងអក្សរ D.P នៅលើជើងទម្រ
- អក្សរ **គណបក្សប្រជាធិបតេយ្យជឿនលឿន** នៅខាងក្រោមជើងទម្រ

អត្ថន័យនៃរូបសញ្ញានេះមានចែងនៅក្នុងឧបសម្ព័ន្ធទី១។

គណបក្សប្រជាធិបតេយ្យជឿនលឿន មានបាវចនា **នីតិរដ្ឋ ភាតរភាព វឌ្ឍនភាព**។

**ប្រការ ៣ ( ថ្មី ) ៖**

ទីស្នាក់ការកណ្តាលគណបក្ស តាំងនៅរាជធានីភ្នំពេញ។ ទីស្នាក់ការនេះអាចផ្លាស់ប្តូរទៅតាំងនៅទីកន្លែងផ្សេងទៀត តាមការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស។

គណបក្សអាចបើកទីស្នាក់ការ ដែលជាសាខានៅរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ ឃុំ-សង្កាត់ និងភូមិទូទាំងប្រទេស និងមានសាខានៅតាមប្រទេសនានាលើសកលលោក។

**ប្រការ ៤ ( ថ្មី ) ៖**

គណបក្សប្រជាធិបតេយ្យជឿនលឿន កំណត់យកថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១ ជាថ្ងៃបង្កើតគណបក្សជាផ្លូវការ ដែលបានសម្រេចដោយក្រុមស្ថាបនិកគណបក្ស។

## ជំពូកទី២
## ទស្សនវិស័យ គោលបំណង និងគោលនយោបាយ

**ប្រការ ៥ ( ថ្មី ) ៖**

គណបក្សប្រជាធិបតេយ្យជឿនលឿន ប្រព្រឹត្តទៅក្នុងក្របខណ្ឌ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៦ ( ថ្មី ) ៖**

គណបក្សប្រជាធិបតេយ្យជឿនលឿន មានទស្សនវិស័យ ឱ្យប្រជាពលរដ្ឋខ្មែរ ធ្វើជាម្ចាស់វាសនា ម្ចាស់ទឹកដីនៃមាតុភូមិកម្ពុជា និងធ្វើជាម្ចាស់អំណាចពិតប្រាកដ ដោយសេចក្តីក្លាហាន មោះមុតអង់អាច គុណធម៌ និងការទទួលខុសត្រូវ។ កសាងកម្ពុជា ជាប្រទេសប្រជាធិបតេយ្យទំនើប ដែលមានយុត្តិធម៌ សេដ្ឋកិច្ចរីកចម្រើន សង្គមសាមគ្គី និងអភិវឌ្ឍបៃតង ដោយមានការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋ។

**ប្រការ ៧ (ថ្មី) ៖**

គណបក្សប្រជាធិបតេយ្យជឿនលឿន មានគោលបំណងប្រមូលផ្តុំកម្លាំងប្រជាពលរដ្ឋខ្មែរ អ្នកស្នេហាជាតិ និងអ្នកប្រជាធិបតេយ្យសេរី ទាំងក្នុងនិងក្រៅប្រទេស រួមគ្នាកសាងគណបក្សប្រជាធិបតេយ្យសេរីនិយមដ៏រឹងមាំមួយនៅកម្ពុជា ដើម្បីបំពេញករណីយកិច្ច ៖

១. ការពារឯករាជ្យភាព អធិបតេយ្យ បូរណភាពទឹកដីខ្មែរ ដោយប្រឆាំងនឹងអំពើឈ្លានពានពីបរទេស តាមគ្រប់រូបភាព

២. លើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ឱ្យមានភាពសមរម្យថ្លៃថ្នូរ ដោយប្រឆាំងនឹងអំពើពុករលួយ និងអយុត្តិធម៌សង្គម

៣. កសាងអនាគតថ្មីដើម្បីកម្ពុជា កសាងរដ្ឋទំនើប សង្គមជឿនលឿន មានអារ្យធម៌ថ្លៃថ្នូរ យុត្តិធម៌ សមធម៌ គោរពសិទ្ធិមនុស្ស តាមគោលការណ៍នីតិរដ្ឋ ប្រជាធិបតេយ្យសេរីពហុបក្ស ដោយប្រឆាំងនឹងអំណាចប្រមូលផ្តុំផ្តាច់ការ។

**ប្រការ ៨ (ថ្មី) ៖**

គណបក្សប្រជាធិបតេយ្យជឿនលឿន មានគោលនយោបាយដោយកំណត់ **គោលការណ៍នយោបាយ** (ប្រាកដនិយម នីតិរដ្ឋ ប្រយោជន៍ជាតិ) **គុណតម្លៃនយោបាយ** (កសាងអនាគតថ្មីដើម្បីកម្ពុជា ជាតិ មាតុភូមិ និងប្រជាពលរដ្ឋ) និង **មាគ៌ានយោបាយ** (មិនប្រកាន់មនោគមវិជ្ជាឆ្វេង ឬស្តាំ តែផ្តោតលើស្មារតី គំនិត និងលទ្ធិកម្ពុជានិយម) មានជាអាទិ៍ ៖

១. នីតិរដ្ឋ ប្រជាធិបតេយ្យសេរីពហុបក្ស

២. លើកស្ទួយការពារ ការគោរពសិទ្ធិមនុស្ស សមភាពយេនឌ័រ ជនមានពិការភាព សមធម៌ខាងនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច

៣. សីលធម៌សង្គម អហិង្សា ខ្មែរតែមួយ ផ្សះផ្សាជាតិ មិនយកខ្មែរណាជាសត្រូវ មិនគុំកួនសងសឹកខ្មែរ

៤. ទទួលខុសត្រូវក្នុងការដឹកនាំតាមគោលការណ៍អភិបាលកិច្ចល្អ

៥. សេដ្ឋកិច្ចទីផ្សារសេរី ដើម្បីសង្គម។

## ជំពូកទី៣

## សមាជិកភាព

**ប្រការ ៩ (ថ្មី) ៖**

គណបក្សប្រជាធិបតេយ្យជឿនលឿន គឺជាអង្គការនយោបាយប្រកាន់យកលទ្ធិប្រជាធិបតេយ្យសេរី និងបើកចំហសម្រាប់ប្រជាពលរដ្ឋខ្មែរពីគ្រប់មជ្ឈដ្ឋាន ដែលគាំទ្រគោលនយោបាយរបស់គណបក្សជាសមាជិករបស់ខ្លួន។ ប្រជាពលរដ្ឋខ្មែរ ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ អាចដាក់ពាក្យសុំចូលជាសមាជិកសកម្មរបស់គណបក្សបាន។

គណៈកម្មាធិការប្រតិបត្តិ ពិនិត្យ និងសម្រេចបញ្ចូលជាសមាជិកសកម្មរបស់គណបក្ស អនុលោមតាមបទបញ្ជាផ្ទៃក្នុងគណបក្ស ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ។

**ប្រការ ១០ ៖**

សមាជិករបស់គណបក្ស មាន៤ប្រភេទ ៖

- សមាជិកស្ថាបនិក

- សមាជិកកិត្តិយស
- សមាជិកសកម្ម
- និងសមាជិកគាំទ្រ។

**ប្រការ ១១ ៖**

សមាជិកស្ថាបនិក គឺជាអ្នកផ្តួចផ្តើមបង្កើតគណបក្ស រៀបចំលក្ខន្តិកៈ និងសមាជលើកដំបូងរបស់គណបក្ស។

**ប្រការ ១២ ៖**

សមាជិកកិត្តិយស គឺជាវរជន ដែលមានឈ្មោះល្បីល្បាញនៅលើឆាកជាតិ និងអន្តរជាតិ ដែលបានជួយឧបត្ថម្ភគាំទ្រយ៉ាងខ្លាំង ទាំងទស្សនវិស័យគំនិតស្មារតី ទាំងមធ្យោបាយដល់គណបក្ស។

**ប្រការ ១៣ ៖**

សមាជិកសកម្ម គឺជាសមាជិក ដែលធ្វើសកម្មភាពតំណាងគណបក្សនៅគ្រប់លំដាប់ថ្នាក់ ស្របតាមគោលនយោបាយរបស់គណបក្ស។ សមាជិកសកម្ម មានកាតព្វកិច្ចបង់ភាគទាន ជូនគណបក្សតាមការសម្រេចរបស់គណបក្ស។

សមាជិកសកម្ម គឺជាអ្នកជ្រើសរើសប្រតិភូតំណាងគណបក្សគ្រប់លំដាប់ថ្នាក់។ សមាជិកសកម្មរបស់គណបក្សអាចមានប័ណ្ណសម្គាល់ខ្លួន ឬមានសេចក្តីសម្រេចតែងតាំងជាផ្លូវការពីគណបក្ស។

**ប្រការ ១៤ ៖**

សមាជិកគាំទ្រ គឺជាអ្នកដែលគាំទ្រគោលនយោបាយរបស់គណបក្សតែមិនចេញមុខធ្វើជាតំណាងគណបក្ស។

**ប្រការ ១៥ ៖**

សមាជិកទាំងអស់របស់គណបក្ស លើកលែងតែសមាជិកគាំទ្រ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនានា ដែលមានចែងក្នុងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងគណបក្ស ហើយត្រូវអនុវត្តគោលនយោបាយ និងសេចក្តីសម្រេចនានារបស់គណបក្ស។

**ប្រការ ១៦ ៖**

សមាជិកគណបក្សអាចបាត់បង់សមាជិកភាពរបស់ខ្លួនដោយ ៖

- មរណភាព
- ការសុំលាលែងជាលាយលក្ខណ៍អក្សរ ដាក់ជូនប្រធានគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ឬដាក់ជូនប្រធានគណបក្ស
- ការបញ្ចប់សមាជិកភាពពីគណបក្ស។

**ប្រការ ១៧ ៖**

ការបញ្ចប់សមាជិកភាពពីគណបក្ស ចំពោះសមាជិករូបណាដែលមិនគោរពលក្ខន្តិកៈ ឬសេចក្តីសម្រេចនានារបស់គណបក្ស ឬធ្វើសកម្មភាពផ្ទុយពីផលប្រយោជន៍គណបក្ស ត្រូវសម្រេចឡើងដោយ ៖

- គណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ហើយមានការបើកផ្លូវតវ៉ារយៈពេល ១៥ថ្ងៃ មកគណៈកម្មាធិការវិន័យរបស់គណបក្ស ចំពោះសមាជិកសកម្មថ្នាក់ក្រុង-ស្រុក-ខណ្ឌ ឃុំ-សង្កាត់ និងភូមិ សេចក្តីសម្រេចរបស់គណៈកម្មាធិការវិន័យ គឺជាការបិទផ្លូវតវ៉ា។

- គណៈកម្មាធិការវិន័យគណបក្ស ហើយមានការបើកផ្លូវតវ៉ារយៈពេល ១៥ថ្ងៃ មកគណៈកម្មាធិការអចិន្ត្រៃយ៍របស់គណបក្ស ចំពោះថ្នាក់ដឹកនាំគណបក្សថ្នាក់ជាតិ និងថ្នាក់រាជធានី-ខេត្ត សេចក្ដីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ គឺជាការបិទផ្លូវតវ៉ា។

ការសម្រេចបញ្ចប់សមាជិកភាពពីគណបក្ស អនុលោមតាមច្បាប់ ស្ដីពីគណបក្សនយោបាយ និងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីគណបក្សនយោបាយ។

សមាជិករូបណាដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្ស ត្រូវបាត់បង់តួនាទីទាំងអស់នៅក្នុងរចនាសម្ព័ន្ធគណបក្សដោយស្វ័យប្រវត្តិ។

## ជំពូកទី៤
## សិទ្ធិ និងករណីយកិច្ចរបស់សមាជិក

**ប្រការ ១៨ ៖**

សមាជិកគណបក្ស មានសិទ្ធិស្មើគ្នាក្នុងការចូលរួមសកម្មភាពជាប្រយោជន៍ដល់គណបក្ស មានសិទ្ធិឈរឈ្មោះជាតំណាងគណបក្សគ្រប់លំដាប់ថ្នាក់ រួមទាំងសិទ្ធិផ្ដល់យោបល់ក្នុងការដឹកនាំគណបក្ស ស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់គណបក្ស។

សមាជិកគណបក្ស ដែលមានប័ណ្ណគណបក្សសម្គាល់ខ្លួន ឬមានសេចក្ដីសម្រេចតែងតាំងជាផ្លូវការ ត្រូវគោរពប្រតិបត្តិឱ្យបានហ្មត់ចត់នូវវិន័យ និងក្រមសីលធម៌ដូចខាងក្រោមនេះ ៖

- រាល់ក្បួនច្បាប់ និងរាល់សេចក្ដីសម្រេចនានារបស់គណបក្ស
- ទំនៀមទម្លាប់ ប្រពៃណីជាតិ និងសាមគ្គីជួយគ្នា ដើម្បីធ្វើឱ្យសមាជិកគណបក្ស កាន់តែមានលក្ខណសម្បត្តិល្អប្រសើរឡើង ក្នុងការបម្រើ ការពារ និងជួយសម្រាលទុក្ខវេទនា របស់ប្រជាពលរដ្ឋ
- រាប់អានគ្នា និងទទួលស្គាល់ភាពថ្លៃថ្នូររបស់សមាជិកគណបក្សទាំងអស់ដោយចៀសវាង គំនិតមើលងាយគ្នា អាត្មានិយម ឬការប្រកាន់ឋានៈ តួនាទី ឬការមើលបំណាំគ្នា
- សេរីភាពខាងជំនឿរបស់សមាជិកទាំងអស់ មិនប្រកាន់ជនជាតិ សាសនា ឬក្រុមបក្ខពួកនៅក្នុងគណបក្ស
- សមភាពយេនឌ័រ ដោយចៀសវាងការប្រមាថ រើសអើង ឬប្រព្រឹត្តិអំពើហិង្សាលើស្ត្រី គ្រប់រូបភាព
- គោរពសិទ្ធិជនពិការ ដោយចៀសវាងការប្រមាថ រើសអើង គ្រប់រូបភាព
- ឥរិយាបថ អាកប្បកិរិយា ថ្លៃថ្នូរ ដោយគោរពផ្ដល់តម្លៃគ្នាទៅវិញទៅមក មិនប្រើពាក្យអសុរោះ ជេរប្រមាថ លាបពណ៌ ញុះញង់បំបែកបំបាក់។

## ជំពូកទី៥
## រចនាសម្ព័ន្ធគណបក្ស

**ប្រការ ១៩ (ថ្មី) ៖**

គណបក្សប្រជាធិបតេយ្យជឿនលឿន មានរចនាសម្ព័ន្ធ ដូចតទៅ ៖

១. សមាជ

២. ក្រុមប្រឹក្សាជាតិ

៣. គណៈកម្មាធិការនាយក

៤. គណៈកម្មាធិការវិន័យ

៥. គណៈកម្មាធិការប្រតិបត្តិ

៦. គណៈកម្មាធិការអចិន្ត្រៃយ៍

៧. រចនាសម្ព័ន្ធគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ។

## ផ្នែកទី១

## សមាជគណបក្ស

**ប្រការ ២០ (ថ្មី) ៖**

សមាជគណបក្ស គឺជាស្ថាប័នកំពូលរបស់គណបក្ស។ សមាជចូលរួមដោយប្រតិភូតំណាងសមាជិកគណបក្ស ដូចមានចែងក្នុងប្រការ២៣(ថ្មី) នៃលក្ខន្តិកៈ។

សមាជមានភារកិច្ច ពិនិត្យ ពិភាក្សា និងអនុម័ត ៖

- លើរបាយការណ៍របស់គណៈកម្មាធិការនៃគណបក្ស
- កំណត់ទិសដៅនយោបាយ និងគោលការណ៍ការងារសំខាន់ៗរបស់គណបក្ស
- អនុម័តលក្ខន្តិកៈគណបក្ស
- ផ្តល់សេចក្តីទុកចិត្តដល់សមាសភាពក្រុមប្រឹក្សាជាតិ
- ផ្តល់សេចក្តីទុកចិត្តដល់សមាសភាពគណៈកម្មាធិការនាយក
- ជ្រើសតាំងប្រធានគណបក្ស

សមាជ ចាត់ទុកជាផ្លូវការបាន លុះត្រាតែមានប្រតិភូតំណាងសមាជិកគណបក្សចូលរួមលើសពីពាក់កណ្តាល។

ការបោះឆ្នោតជ្រើសតាំងប្រធានគណបក្ស ត្រូវបោះឆ្នោតដោយផ្ទាល់ និងសម្ងាត់ពីសមាជិកវត្តមានដែលមានសិទ្ធិសម្រេច។

ការអនុម័ត ឬការបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត ត្រូវសម្រេចដោយសំឡេងភាគច្រើនដាច់ខាត(៥០%+១) នៃសមាជិកដែលមានសិទ្ធិសម្រេចទាំងមូល តាមរយៈការបោះឆ្នោតដោយចំហ។

ការអនុម័តលើលក្ខន្តិកៈគណបក្ស ត្រូវអនុម័តដោយសំឡេងភាគច្រើន(២/៣)នៃសមាជិកវត្តមានដែលមានសិទ្ធិសម្រេច តាមរយៈការបោះឆ្នោតដោយចំហ។

**ប្រការ ២១ (ថ្មី) ៖**

សមាជ មានពីរប្រភេទ គឺ សមាជសាមញ្ញ និងសមាជវិសាមញ្ញ។

១. សមាជសាមញ្ញ នឹងប្រារព្ធឡើងជាទៀងទាត់ រៀងរាល់៥ឆ្នាំម្តង លើកលែងករណីប្រធានសក្តិ។ កាលបរិច្ឆេទ និងទីកន្លែងនៃសមាជនេះ នឹងកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស។

២. សមាជវិសាមញ្ញ នឹងប្រារព្ធឡើងអាស្រ័យទៅតាមការសម្រេចរបស់ប្រធានគណបក្ស ដោយមានការគាំទ្រដោយសំឡេងភាគច្រើន(២/៣)នៃសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ទាំងមូល ឬតាមសំណើ ២/៣ នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល ដោយមានការគាំទ្រពីប្រធានគណៈកម្មាធិការនាយក។

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស មានភារកិច្ចកោះប្រជុំ និងរៀបចំសមាជសាមញ្ញ និងវិសាមញ្ញ ហើយសមាជទាំងពីរប្រភេទនេះ ត្រូវតែប្រារព្ធឡើងក្រោមអធិបតីភាពរបស់ប្រធានគណបក្ស ឬប្រធានសមាជ។

**ប្រការ ២២ ៖**

ការអញ្ជើញសមាជិកគណបក្សមកចូលរួមសមាជ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងតិច១៥ថ្ងៃជាមុន ចំពោះសមាជសាមញ្ញ និង៧ថ្ងៃជាមុនចំពោះសមាជវិសាមញ្ញ ដោយមានបញ្ជាក់នូវរបៀបវារៈរបស់សមាជ។

សមាជិកគណបក្ស ដែលមានលក្ខណៈជាប្រតិភូតំណាង ហើយត្រូវអញ្ជើញមកចូលរួមសមាជ មានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងគណបក្ស។

## ផ្នែកទី២

## ក្រុមប្រឹក្សាជាតិ

**ប្រការ ២៣ ( ថ្មី ) ៖**

ក្រុមប្រឹក្សាជាតិ ជាស្ថាប័នជាន់ខ្ពស់របស់គណបក្ស ដែលអាចជួបប្រជុំ២ឆ្នាំម្តង ហៅថាសន្និបាតក្រុមប្រឹក្សាជាតិ។ ក្រុមប្រឹក្សាជាតិ ជាប្រតិភូតំណាងឱ្យសមាជិកគណបក្សពីមូលដ្ឋាន និងមជ្ឈដ្ឋាននានា ដើម្បីចូលរួមសមាជគណបក្ស។

ក្រុមប្រឹក្សាជាតិ មានសមាជិកយ៉ាងតិច ២៧រូប។

សមាសភាពក្រុមប្រឹក្សាជាតិតំណាងពី ៖

- គណៈកម្មាធិការអចិន្ត្រៃយ៍ ( យ៉ាងតិច ៣នាក់ )
- គណៈកម្មាធិការនាយក ( យ៉ាងតិច ៣នាក់ )
- គណៈកម្មាធិការវិន័យ ( យ៉ាងតិច ២នាក់ )
- គណៈកម្មាធិការប្រតិបត្តិ ( យ៉ាងតិច ៧នាក់ )
- ក្រុមការងាររាជធានី-ខេត្ត ( យ៉ាងតិច ៣នាក់ )
- គណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ( យ៉ាងតិច ៣នាក់ )
- ប្រធាន និងអនុប្រធាន ចលនាមហាជនថ្នាក់ជាតិ ( យ៉ាងតិច ៣នាក់ )
- ប្រធានគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ ( យ៉ាងតិច ៣នាក់ )

សមាសភាពក្រុមប្រឹក្សាជាតិនេះ កំណត់ដូចមានចែងក្នុងប្រការ៥៨(ថ្មី) នៃលក្ខន្តិកៈគណបក្ស និងត្រូវបានផ្តល់សេចក្តីទុកចិត្តដោយសមាជគណបក្ស។

**ប្រការ ២៤ ៖**

សន្និបាតក្រុមប្រឹក្សាជាតិ អាចប្រារព្ធឡើងរៀងរាល់២ឆ្នាំម្តង ឬតាមការចាំបាច់។ ទីកន្លែង កាលបរិច្ឆេទ និងរបៀបវារៈនៃសន្និបាតនេះ នឹងកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស។

សន្និបាតក្រុមប្រឹក្សាជាតិ ត្រូវប្រារព្ធឡើងក្រោមអធិបតីភាពរបស់ប្រធានគណបក្ស ឬអនុប្រធានគណបក្សតាមការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្ស។

សន្និបាតក្រុមប្រឹក្សាជាតិ ៖

- ធ្វើការពិភាក្សា អនុម័ត ឬផ្តល់សេចក្តីទុកចិត្តសេចក្តីសម្រេចនានារបស់គណបក្ស ដែលដាក់ជូនដោយគណៈកម្មាធិការនាយក ចន្លោះសមាជ
- អនុម័តគោលនយោបាយសំខាន់ៗរបស់គណបក្ស។

សន្និបាតក្រុមប្រឹក្សាជាតិអាចប្រព្រឹត្តទៅបាន ចាំបាច់ត្រូវមានកូរ៉ុមភាគច្រើនដាច់ខាត(៥០%+១)នៃសមាជិកក្រុមប្រឹក្សាជាតិទាំងមូល។ សេចក្ដីសម្រេចរបស់សន្និបាតក្រុមប្រឹក្សាជាតិ ត្រូវអនុម័តដោយសំឡេងភាគច្រើនដាច់ខាត(៥០%+១)នៃសមាជិកវត្តមាន។

ការរៀបចំ និងការប្រព្រឹត្តិទៅរបស់សន្និបាតក្រុមប្រឹក្សាជាតិ និងសមាជ មានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងគណបក្ស។

## ផ្នែកទី៣
## គណៈកម្មាធិការនាយក

**ប្រការ ២៥ (ថ្មី) ៖**

គណៈកម្មាធិការនាយក គឺជាស្ថាប័ននីតិប្បញ្ញត្តិរបស់គណបក្ស។

គណៈកម្មាធិការនាយកអនុវត្តតាមទិសដៅ និងគោលនយោបាយរបស់គណបក្ស ដែលកំណត់ដោយសមាជ ឬសន្និបាតក្រុមប្រឹក្សាជាតិ។

គណៈកម្មាធិការនាយក មានសមាជិកយ៉ាងតិច ២៥រូប ដែលផ្ដល់សេចក្ដីទុកចិត្តដោយសមាជគណបក្ស សម្រាប់អាណត្តិ ៥ឆ្នាំ។ បេក្ខជនគណៈកម្មាធិការនាយកត្រូវបានជ្រើសរើស ៖

- មកពីក្រុមការងារគណបក្សរាជធានី-ខេត្ត ដែលជ្រើសរើសដោយសមាជិកក្រុមប្រឹក្សាជាតិ តំណាងរាជធានី-ខេត្ត និងប្រធានគណៈកម្មាធិការប្រតិបត្តិ ឃុំ-សង្កាត់ក្នុងរាជធានី-ខេត្តសាមី។ ចំនួនបេក្ខជនគណៈកម្មាធិការនាយក តំណាងគណបក្សរាជធានី-ខេត្តនីមួយៗ មានចំនួនយ៉ាងច្រើនស្មើនឹងអាសនៈតំណាងរាស្ត្រក្នុងរាជធានី-ខេត្តសាមី បូកមួយ ចែកនឹងពីរ ដោយសំឡេងគាំទ្រភាគច្រើនតាមលំដាប់។
- តាមសំណើរបស់ប្រធានគណបក្ស ហើយចំនួនបេក្ខជនគណៈកម្មាធិការនាយកដែលជ្រើសរើសនេះ មិនត្រូវ លើសចំនួន ១/៣ នៃសមាជិកគណៈកម្មាធិការនាយកមកពីតំណាងគណបក្ស រាជធានី-ខេត្ត ដោយត្រូវផ្ដល់ អាទិភាពដល់យុវជន ស្ត្រី និងតំណាងសាខាគណបក្សក្រៅប្រទេស តាមរយៈការបោះឆ្នោតសម្ងាត់ ដោយសំឡេងភាគច្រើនដាច់ខាត (៥០%+១)នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល។

សមាជិកគណៈកម្មាធិការនាយក ត្រូវបានបញ្ចប់មុខងារ ដូចមានចែងក្នុងប្រការ១៦ ប្រការ១៧ និងប្រការ ២៩(ថ្មី) នៃលក្ខន្តិកៈនេះ។

**ប្រការ ២៦ ៖**

គណៈកម្មាធិការនាយក ផ្ដល់សេចក្ដីទុកចិត្តដល់សមាសភាពគណៈកម្មាធិការប្រតិបត្តិថ្នាក់ជាតិ តាមសំណើរបស់ប្រធានគណបក្ស។

គណៈកម្មាធិការនាយក បង្កើតគណៈកម្មាធិការវិន័យគណបក្សដូចមានចែងក្នុងផ្នែកទី៥ នៃលក្ខន្តិកៈនេះ។

គណៈកម្មាធិការនាយក ជ្រើសតាំងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស។

គណៈកម្មាធិការនាយក អាចបង្កើតគណៈកម្មការនានាតាមការចាំបាច់។

**ប្រការ ២៧ ៖**

គណៈកម្មាធិការនាយក ត្រួតពិនិត្យការប្រតិបត្តិរបស់គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស និងអាចផ្ដួចផ្ដើមគំនិតឱ្យគណៈកម្មាធិការអចិន្ត្រៃយ៍ដឹកនាំគណបក្ស ស្របតាមស្ថានការណ៍ និងកាលៈទេសៈជាក់ស្ដែង ដើម្បីឱ្យគណបក្សមានការរីកចម្រើន។

គណៈកម្មាធិការនាយក ពិភាក្សា អនុម័ត រាល់បទប្បញ្ញត្តិផ្សេងៗរបស់គណបក្ស តាមសំណើរបស់គណៈកម្មាធិការអចិន្ត្រៃយ៍។

**ប្រការ ២៨ ៖**

គណៈកម្មាធិការនាយក ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានយ៉ាងតិចមួយរូប។

ប្រធានគណៈកម្មាធិការនាយក ជ្រើសតាំងដោយសមាជិកគណៈកម្មាធិការនាយក តាមរយៈការបោះឆ្នោតសម្ងាត់ ដោយសំឡេងភាគច្រើន (៥០%+១) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល។

បេក្ខជនប្រធានគណៈកម្មាធិការនាយក ជាសមាជិកគណៈកម្មាធិការនាយក ដែលមានការគាំទ្រពីសមាជិកគណៈកម្មាធិការនាយកចំនួនយ៉ាងតិច ១/៣ នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល។

អនុប្រធានគណៈកម្មាធិការនាយក ជាសមាជិកគណៈកម្មាធិការនាយក ត្រូវបានផ្តល់ការយល់ព្រមដោយសំឡេងភាគច្រើន (៥០%+១) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល តាមសំណើរបស់ប្រធានគណៈកម្មាធិការនាយក។

**ប្រការ ២៩ (ថ្មី) ៖**

គណៈកម្មាធិការនាយក មានអាណត្តិ៥ឆ្នាំ។ សមាជិកគណៈកម្មាធិការនាយកចាស់នឹងអស់សុពលភាពនៅពេល សមាជិកគណៈកម្មាធិការនាយកថ្មីចូលកាន់តំណែង។

នីតិវិធីនៃការបោះឆ្នោតជ្រើសតាំង និងការចូលកាន់តំណែងប្រធានគណៈកម្មាធិការនាយក មានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងគណបក្ស។

ក្នុងករណីចាំបាច់ តាមសំណើរបស់ប្រធានគណបក្ស ឬ១/៤ នៃសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ឬ១/៤ នៃគណៈកម្មាធិការនាយក អាចស្នើជ្រើសតាំងបន្ថែម ឬបំពេញបន្ថែមនូវសមាជិកគណៈកម្មាធិការនាយក ដើម្បីបំពេញការងារតាមតម្រូវការចាំបាច់មុនពេល ឬចន្លោះសមាជ ដូចមានចែងក្នុងប្រការ៥៨(ថ្មី) នៃលក្ខន្តិកៈនេះ។

**ប្រការ ៣០ ៖**

គណៈកម្មាធិការនាយក ជួបប្រជុំគ្នាយ៉ាងតិច ៣ខែម្តង។ ក្នុងករណីចាំបាច់ ប្រធានគណបក្ស ឬប្រធានគណៈកម្មាធិការនាយក ឬតាមសំណើ ១/៣ នៃសមាជិកគណៈកម្មាធិការនាយក មានសិទ្ធិកោះប្រជុំគណៈកម្មាធិការនាយក។

កិច្ចប្រជុំរបស់គណៈកម្មាធិការនាយក ត្រូវមានកូរ៉ុម (៥០%+១) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល។

សេចក្តីសម្រេចនៃកិច្ចប្រជុំរបស់គណៈកម្មាធិការនាយក ត្រូវមានសំឡេងភាគច្រើនដាច់ខាត(៥០%+១)នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល។

## ផ្នែកទី៤
## គណៈកម្មាធិការវិន័យ

**ប្រការ ៣១ ៖**

គណៈកម្មាធិការវិន័យ គឺជាស្ថាប័នដោះស្រាយវិវាទរបស់គណបក្ស។

គណៈកម្មាធិការវិន័យ ត្រូវបានបង្កើតឡើងដោយគណៈកម្មាធិការនាយក។

គណៈកម្មាធិការវិន័យ មានតួនាទី និងភារកិច្ច ដូចតទៅ ៖

- ទទួលពាក្យបណ្តឹងវិវាទរបស់សមាជិកគណបក្ស
- ទទួលពាក្យបណ្តឹងស្តីពីភាពមិនប្រក្រតី នៃចំណូល-ចំណាយរបស់គណបក្ស

- ទទួលបណ្ដឹងឧទ្ធរណ៍ ករណីបញ្ចប់សមាជិកភាពដោយគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត
- ដាក់ពិន័យសមាជិកគណបក្សរូបណា ដែលរំលោភបទប្បញ្ញត្តិដែលមានចែងក្នុងប្រការ១៨ នៃលក្ខន្តិកៈគណបក្ស។

នីតិវិធីនៃការដោះស្រាយបណ្ដឹង ការដាក់ពិន័យ និងការបញ្ចប់សមាជិកភាព មានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងគណបក្ស។

**ប្រការ ៣២ ៖**

គណៈកម្មាធិការវិន័យ មានសមាសភាពដូចតទៅ ៖

- ប្រធាន និងអនុប្រធានមួយរូប ជ្រើសរើសដោយគណៈកម្មាធិការនាយកពីក្នុងចំណោមសមាជិករបស់ខ្លួន ដោយសំឡេងគាំទ្រភាគច្រើនដាច់ខាត (៥០%+១) នៃចំនួនសមាជិកគណៈកម្មាធិការនាយកទាំងមូល
- សមាជិកប្រាំរូបទៀត ជ្រើសរើសដោយគណៈកម្មាធិការនាយកពីក្នុងចំណោមសមាជិកក្រុមប្រឹក្សាជាតិ ដោយសំឡេងគាំទ្រភាគច្រើនដាច់ខាត (៥០%+១) នៃចំនួនសមាជិកគណៈកម្មាធិការនាយកទាំងមូល។

បេក្ខជនប្រធាន និងអនុប្រធាន ត្រូវមានការគាំទ្រពីសមាជិកគណៈកម្មាធិការនាយកចំនួនយ៉ាងតិច ១/៣ នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល។

**ប្រការ ៣៣ ៖**

គណៈកម្មាធិការវិន័យ មានអាណត្តិ ៥ឆ្នាំ។ គណៈកម្មាធិការវិន័យចាស់នឹងអស់សុពលភាពបន្ទាប់ពីគណៈកម្មាធិការវិន័យថ្មីចូលកាន់តំណែង។

**ប្រការ ៣៤ ៖**

គណៈកម្មាធិការវិន័យ ជួបប្រជុំគ្នាយ៉ាងតិច ៣ខែម្តង។ ក្នុងករណីមានបណ្ដឹង ប្រធាន ឬអនុប្រធានគណៈកម្មាធិការវិន័យ ត្រូវកោះប្រជុំគណៈកម្មាធិការវិន័យ ក្នុងរយៈពេល ៧ថ្ងៃយ៉ាងយូរ ក្រោយពេលទទួលបានពាក្យបណ្ដឹង។

កិច្ចប្រជុំរបស់គណៈកម្មាធិការវិន័យ ត្រូវមានកូរ៉ុម(៥០%+១)នៃសមាជិកគណៈកម្មាធិការវិន័យទាំងមូល។

សេចក្ដីសម្រេចនៃកិច្ចប្រជុំរបស់គណៈកម្មាធិការវិន័យ ត្រូវមានសំឡេងភាគច្រើនដាច់ខាត(៥០%+១) នៃសមាជិកគណៈកម្មាធិការវិន័យទាំងមូល។

សមាជិកគណៈកម្មាធិការវិន័យ ត្រូវបានបញ្ចប់មុខងារ ដូចមានចែងក្នុងប្រការ១៦ ប្រការ១៧ នៃលក្ខន្តិកៈ។

## ផ្នែកទី៥
## គណៈកម្មាធិការប្រតិបត្តិ

**ប្រការ ៣៥ ៖**

គណៈកម្មាធិការប្រតិបត្តិ គឺជាស្ថាប័ននីតិប្រតិបត្តិរបស់គណបក្ស។

គណៈកម្មាធិការប្រតិបត្តិ ដឹកនាំ ចាត់ចែង និងអនុវត្តកិច្ចការប្រចាំថ្ងៃរបស់គណបក្ស តាមសេចក្ដីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការនាយក។

គណៈកម្មាធិការប្រតិបត្តិគ្រប់គ្រង និង ធានាការប្រព្រឹត្តិទៅរបស់គណបក្ស ព្រមទាំងរចនាសម្ព័ន្ធគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ និងសាខាគណបក្សនៅក្រៅប្រទេស។

**ប្រការ ៣៦ ៖**

ប្រធាន អនុប្រធាន និងអគ្គលេខាធិការ គណៈកម្មាធិការប្រតិបត្តិ ជាប្រធាន អនុប្រធាន និងអគ្គលេខាធិការ គណបក្ស។

**ប្រការ ៣៧ ៖**

គណៈកម្មាធិការប្រតិបត្តិ មានសមាសភាពជ្រើសចេញមកពីសមាជិកគណៈកម្មាធិការនាយក។

សមាសភាពគណៈកម្មាធិការប្រតិបត្តិ រួមមាន៖

- ប្រធាន មួយរូប
- អនុប្រធាន យ៉ាងតិចមួយរូប
- អគ្គលេខាធិការ មួយរូប អមដោយអគ្គលេខាធិការរង យ៉ាងតិចមួយរូប
- ហេរញ្ញិក មួយរូប អមដោយហេរញ្ញិករង មួយរូប។

**ប្រការ ៣៨ ៖**

អនុប្រធាន អគ្គលេខាធិការ អគ្គលេខាធិការរង ហេរញ្ញិក ហេរញ្ញិករង ស្នើសុំតែងតាំងដោយ ប្រធានគណៈកម្មាធិការប្រតិបត្តិ ហើយត្រូវផ្ដល់សេចក្ដីទុកចិត្តពីគណៈកម្មាធិការនាយក ដោយសំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល។

អនុប្រធានគណៈកម្មាធិការប្រតិបត្តិ ទទួលការងារតាមការកំណត់របស់ប្រធានគណៈកម្មាធិការប្រតិបត្តិ។

គណៈកម្មាធិការប្រតិបត្តិ មានអគ្គលេខាធិការដ្ឋាន ជាសេនាធិការ។

**ប្រការ ៣៩ ៖**

អគ្គលេខាធិការដ្ឋាន ដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងយ៉ាងតិចមួយរូប។

អគ្គលេខាធិការដ្ឋាន មាននាយកដ្ឋានមួយចំនួនតាមតម្រូវការចាំបាច់។ នាយកដ្ឋាននីមួយៗ ដឹកនាំដោយ ប្រធាននាយកដ្ឋានមួយរូប ដែលតែងតាំងដោយប្រធានគណៈកម្មាធិការប្រតិបត្តិ តាមសំណើរបស់អគ្គលេខាធិការ។

ការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន កំណត់ដោយគណៈកម្មាធិការប្រតិបត្តិ។

**ប្រការ ៤០ ៖**

នាយកដ្ឋានហិរញ្ញវត្ថុ ដឹកនាំដោយហេរញ្ញិកមួយរូប អមដោយហេរញ្ញិករងមួយរូប។

ហេរញ្ញិក ទទួលបន្ទុកគ្រប់គ្រងថវិកា និងបញ្ជីសារពើភ័ណ្ឌទាំងអស់របស់គណបក្ស។

ហេរញ្ញិក ត្រូវធ្វើរបាយការណ៍ប្រចាំខែ ស្ដីពីប្រាក់ចំណូល-ចំណាយរបស់គណបក្ស ជូនអគ្គលេខាធិការ និង ប្រធានគណៈកម្មាធិការប្រតិបត្តិ។

**ប្រការ ៤១ ៖**

គណៈកម្មាធិការប្រតិបត្តិ ជួបប្រជុំគ្នាយ៉ាងតិច ៣ខែម្ដង។ ប្រធាន ឬអនុប្រធាន ឬអគ្គលេខាធិការ អាចកោះប្រជុំបានតាមតម្រូវការចាំបាច់។

កិច្ចប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ ត្រូវមានកូរ៉ុម(៥០%+១)នៃសមាជិកគណៈកម្មាធិការប្រតិបត្តិទាំងមូល។

សេចក្ដីសម្រេចនៃកិច្ចប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ ត្រូវមានសំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកគណៈកម្មាធិការប្រតិបត្តិទាំងមូល។

សមាជិកគណៈកម្មាធិការប្រតិបត្តិ ត្រូវបានបញ្ចប់មុខងារ ដូចមានចែងក្នុងប្រការ១៦ និងប្រការ១៧ នៃលក្ខន្តិកៈ។

គណៈកម្មាធិការប្រតិបត្តិមានអាណត្តិ ៥ឆ្នាំ។ គណៈកម្មាធិការប្រតិបត្តិចាស់នឹងអស់សុពលភាព បន្ទាប់ពីគណៈកម្មាធិការប្រតិបត្តិថ្មីចូលកាន់តំណែង។

## ផ្នែកទី៦
## គណៈកម្មាធិការអចិន្ត្រៃយ៍

**ប្រការ ៤២ ៖**

គណៈកម្មាធិការអចិន្ត្រៃយ៍ដឹកនាំ កំណត់មនោគមន៍វិជ្ជា គោលការណ៍ ចក្ខុវិស័យ យុទ្ធសាស្ត្រ និងគោលនយោបាយរបស់គណបក្ស។

គណៈកម្មាធិការអចិន្ត្រៃយ៍ អាចស្នើសុំតែងតាំងអតីតប្រធានគណបក្ស ជាប្រធានកិត្តិយស ហើយត្រូវផ្តល់សេចក្តីទុកចិត្តពីគណៈកម្មាធិការនាយក ដោយសំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល។

គណៈកម្មាធិការអចិន្ត្រៃយ៍ មានសិទ្ធិសម្រេចលើគ្រប់បញ្ហា និងការងារចាំបាច់ រួមទាំងការបញ្ចប់សមាជិកភាព និងស្នើសុំឱ្យប្រធានគណបក្ស តែងតាំង ឬដកតួនាទី ឬព្យួរតំណែង មន្ត្រីគណបក្សគ្រប់លំដាប់ថ្នាក់។ គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ទទួលខុសត្រូវលើរាល់សេចក្តីសម្រេចទាំងនោះ នៅចំពោះមុខគណៈកម្មាធិការនាយក។

**ប្រការ ៤៣ ៖**

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស រៀបចំគម្រោងផែនការធំៗ ដាក់ជូនគណៈកម្មាធិការនាយកពិនិត្យ មុននឹងដាក់ជូនសមាជ ឬសន្និបាតក្រុមប្រឹក្សាជាតិ ពិភាក្សា និងអនុម័ត។

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស មានចំនួនយ៉ាងច្រើន ២៧រូប ដែលមានសមាសភាពដូចតទៅ ៖

- ប្រធាន និងអនុប្រធានគណបក្ស
- ប្រធាន គណៈកម្មាធិការនាយក
- ប្រធាន គណៈកម្មាធិការវិន័យ
- អគ្គលេខាធិការ
- និងសមាជិកមួយចំនួន ដែលជ្រើសរើសដោយគណៈកម្មាធិការនាយក ពីក្នុងចំណោមសមាជិករបស់ខ្លួន តាមសំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល។

ប្រធាន និងអនុប្រធានគណបក្ស ជាប្រធាន និងអនុប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍។

កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ អាចប្រព្រឹត្តទៅបានតាមការសម្រេចរបស់ប្រធាន ឬតាមសំណើចំនួន ១/៣ នៃសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ហើយចាំបាច់ត្រូវមានកូរ៉ុម ២/៣ នៃសមាជិកទាំងមូល។

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវមានសំឡេងគាំទ្រភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកទាំងមូល។

គណៈកម្មាធិការអចិន្ត្រៃយ៍ ជួបប្រជុំគ្នាយ៉ាងតិច ៣ខែម្តង។ ប្រធាន ឬអនុប្រធាន អាចកោះប្រជុំបានតាមតម្រូវការចាំបាច់។

សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវបានបញ្ចប់មុខងារ ដូចមានចែងក្នុងប្រការ១៦ និងប្រការ១៧ នៃលក្ខន្តិកៈ។

**ប្រការ ៤៤ ៖**

ប្រធានគណបក្ស ត្រូវបានជ្រើសតាំងដោយសមាជ តាមរយៈការអនុម័តសំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកវត្តមានដែលមានសិទ្ធិសម្រេច សម្រាប់អាណត្តិ ៥ឆ្នាំ។

បេក្ខជនប្រធានគណបក្ស ជាសមាជិកគណៈកម្មាធិការនាយក ហើយត្រូវមានការគាំទ្រពីសមាជិកគណៈកម្មាធិការនាយក ចំនួនយ៉ាងតិច ១/៣ នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល។

ឥស្សរជននយោបាយមួយរូប ជាសមាជិកគណៈកម្មាធិការនាយកក្នុងគណបក្ស អាចធ្វើជាប្រធានគណបក្ស ត្រឹមពីរអាណត្តិ(១០ឆ្នាំ)។

**ប្រការ ៤៥ (ថ្មី) ៖**

អនុប្រធានគណបក្ស ទទួលដឹកនាំការងារគណបក្ស តាមការកំណត់របស់ប្រធានគណបក្ស។

នៅពេលអវត្តមានប្រធាន អនុប្រធានមួយរូប ត្រូវបានទទួលសិទ្ធិជាប្រធានស្តីទីគណបក្ស តាមរយៈលិខិតផ្ទេរសិទ្ធិ ដែលមានបុព្វសិទ្ធិ ដូចប្រធានគណបក្ស។

ក្នុងករណីអវត្តមានប្រធាន និងអនុប្រធានទាំងអស់ ហើយពុំមានលទ្ធភាពក្នុងការផ្ទេរសិទ្ធបាន អ្នកទទួលសិទ្ធិជាប្រធានស្តីទីគណបក្ស ដោយស្វ័យប្រវត្តិ ត្រូវអនុវត្តតាមឋានានុក្រម ដូចខាងក្រោម៖

១. ប្រធានគណៈកម្មាធិការនាយក

២. ប្រធានគណៈកម្មាធិការវិន័យ

៣. អនុប្រធានគណៈកម្មាធិការនាយក

៤. អនុប្រធានគណៈកម្មាធិការវិន័យ

៥. អគ្គលេខាធិការ

**ប្រការ ៤៦ ៖**

ប្រធានគណបក្ស អាចបង្កើតក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ពីយុទ្ធសាស្ត្រនយោបាយគណបក្ស តាមតម្រូវការចាំបាច់។

ប្រធានគណបក្ស មានខុទ្ទកាល័យមួយ ដើម្បីជួយដល់កិច្ចការផ្ទាល់របស់ខ្លួន។ ខុទ្ទកាល័យប្រធានគណបក្ស ដឹកនាំដោយនាយខុទ្ទកាល័យមួយរូប អមដោយនាយរងខុទ្ទកាល័យមួយចំនួនដែលតែងតាំងដោយប្រធានគណបក្ស។

ប្រធានគណបក្ស តែងតាំង ឬផ្លាស់ប្តូរបេក្ខជនតំណាងរាស្ត្រ បេក្ខជនសមាជិកព្រឹទ្ធសភា និងបេក្ខជនថ្នាក់ដឹកនាំ ដទៃទៀត តាមសំណើរបស់គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស។

ប្រធានគណបក្ស មានសិទ្ធិតែងតាំង ឬដកតួនាទី បេសកជន និងទីប្រឹក្សាផ្ទាល់របស់ខ្លួន។

**ប្រការ ៤៧ (ថ្មី) ៖**

ករណីប្រធានគណបក្ស ទទួលមរណភាព លាឈប់ បាត់បង់សមាជិកភាព ឬបាត់បង់សមត្ថភាព ដឹកនាំគណបក្ស ដែលបញ្ជាក់ដោយគណៈកម្មាធិការនាយក បើ ៖

- អាណត្តិនៅតិចជាង១៨ខែ អនុប្រធានគណបក្សមួយរូប ដែលមានអាយុច្រើនជាងគេ ត្រូវទទួលនាទីជាប្រធានគណបក្ស ហើយបើគ្មានអនុប្រធានគណបក្ស គណៈកម្មាធិការនាយក ត្រូវជ្រើសរើសអនុប្រធានគណបក្សថ្មីយ៉ាងតិចមួយរូប ក្នុងរយៈពេល៣ខែយ៉ាងយូរ ពីក្នុងចំណោមសមាជិករបស់ខ្លួន ដោយ

សំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល ដើម្បីជួយសម្រួលការងារប្រធានគណបក្ស រហូតដល់ចប់អាណត្តិ។

- អាណត្តិនៅលើស១៨ខែ គណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវកំណត់ពេលរៀបចំធ្វើសមាជវិសាមញ្ញ ដើម្បីជ្រើសរើសប្រធានគណបក្ស និងអនុប្រធានគណបក្សថ្មី ក្នុងរយៈពេលយ៉ាងយូរ៣ខែ ដើម្បីដឹកនាំគណបក្សរហូតដល់ចប់អាណត្តិ។

ករណីថ្នាក់ដឹកនាំថ្នាក់ជាតិរបស់គណបក្ស ត្រូវបាត់បង់សមត្ថភាពដឹកនាំគណបក្សទាំងស្រុង ថ្នាក់ដឹកនាំសំខាន់ៗរបស់គណបក្សដែលនៅមានសមត្ថភាព ឬថ្នាក់ដឹកនាំថ្នាក់ក្រោមជាតិ ឬស្ថាបនិករបស់គណបក្ស ត្រូវបង្កើត គណៈកម្មាការបណ្តោះអាសន្នមួយ ដូចមានចែងក្នុងជំពូកទី៩ នៃលក្ខន្តិកៈនេះ ដើម្បីរៀបចំសម្រេចដឹកនាំគណបក្សបន្ត។

## ផ្នែកទី៧
## រចនាសម្ព័ន្ធគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ

**ប្រការ ៤៨ ៖**

រចនាសម្ព័ន្ធគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិមាន ៖

- តំណាងគណបក្សភូមិ
- គណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់
- គណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ
- គណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត

នីតិវិធី នៃការរៀបចំរចនាសម្ព័ន្ធគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ មានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងគណបក្ស។

## ជំពូកទី៦
## ធនធាន និងថវិការបស់គណបក្ស

**ប្រការ ៤៩ ៖**

ធនធាន និងថវិការបស់គណបក្សបានមកពី ៖

- វិភាគទាន ឬភាគទានរបស់សមាជិក
- ចំណូលផ្សេងៗរបស់គណបក្ស ដែលបានមកពីការធ្វើអាជីវកម្មស្របច្បាប់
- ប្រាក់ពីថវិការបស់រដ្ឋតាមការកំណត់ ដូចមានចែងក្នុងច្បាប់ស្តីពីគណបក្សនយោបាយ
- អំណោយរបស់ក្រុមហ៊ុនឯកជនខ្មែរ ឬសប្បុរសជនខ្មែរ
- ទ្រព្យសម្បត្តិផ្ទាល់របស់គណបក្ស។

**ប្រការ ៥០ ៖**

ធនធាន និងថវិកាគណបក្សគ្រប់គ្រងដោយនាយកដ្ឋានហិរញ្ញវត្ថុគណបក្ស។

គណៈកម្មាធិការនាយក ជ្រើសរើសស្នងការគណនេយ្យតាមសំណើរបស់គណៈកម្មាធិការវិន័យ ដើម្បីត្រួតពិនិត្យភាពមិនប្រក្រតីលើបញ្ជីចំណូល-ចំណាយនៃនាយកដ្ឋានហិរញ្ញវត្ថុ។

## ជំពូកទី៧
## ការចងសម្ព័ន្ធភាព ការរួមបញ្ចូលគ្នា ការកែប្រែលក្ខន្តិកៈ និងការរំលាយគណបក្ស

**ប្រការ ៥១ (ថ្មី) ៖**

គណបក្សនេះ អាចធ្វើសម្ព័ន្ធភាពទ្វេភាគី ឬពហុភាគី ឬរួមបញ្ចូលគ្នា ជាមួយគណបក្សនយោបាយដទៃទៀត តាមការសម្រេចរបស់គណៈកម្មាធិការនាយក ដោយសំឡេងភាគច្រើនដាច់ខាត(៥០%+១) នៃសមាជិកទាំងមូល។

សមាជគណបក្ស គឺជាស្ថាប័នតែមួយគត់ ដែលមានសមត្ថកិច្ចធ្វើការកែប្រែលក្ខន្តិកៈ ឬរំលាយគណបក្ស។

ការកោះប្រជុំសមាជ ក្នុងគោលបំណងកែប្រែលក្ខន្តិកៈ ឬរំលាយគណបក្ស ត្រូវមានការយល់ព្រមដោយសំឡេងភាគច្រើន (២/៣) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល ហើយត្រូវមានការយល់ព្រមពីប្រធានគណបក្ស និងប្រធានគណៈកម្មាធិការវិន័យ។

**ប្រការ ៥២ ៖**

ករណីគណបក្សត្រូវរំលាយ ទ្រព្យសម្បត្តិទាំងអស់របស់គណបក្ស បន្ទាប់ពីមានការជម្រះបញ្ជីរួចរាល់ ត្រូវប្រគល់ជូនអង្គការមនុស្សធម៌នានា ដែលកំណត់ដោយសមាជចុងក្រោយរបស់គណបក្ស។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**ប្រការ ៥៣ ៖**

អន្តរប្បញ្ញត្តិ គឺជាប្បញ្ញត្តិសម្រាប់អនុវត្តនៅក្នុងអន្តរកាល។ អន្តរកាល គឺជាដំណាក់កាលនៃការគ្រប់គ្រង និងដឹកនាំសម្រាប់អាណត្តិទី១ របស់គណបក្ស។

**ប្រការ ៥៤ (ថ្មី) ៖**

គណបក្សនេះ ផ្តួចផ្តើមបង្កើតដំបូង គឺមានឈ្មោះថា គណបក្សកម្ពុជានិយម ដោយសមាជិកស្ថាបនិក ដែលមានទស្សនៈនយោបាយដូចគ្នា និងដែលអនុវត្តទៅតាមការកំណត់នៃច្បាប់ស្តីពីគណបក្សនយោបាយ ក្នុងការសុំបង្កើតគណបក្ស រួចស្នើសុំចុះបញ្ជីគណបក្ស ដើម្បីទទួលបានសុពលភាពនៅក្រសួងមហាផ្ទៃ។

## ជំពូកទី៩
## គណៈកម្មាធិការបណ្តោះអាសន្ន

**ប្រការ ៥៥ (ថ្មី) ៖**

សមាជិកស្ថាបនិក ឬសមាជិកក្រុមប្រឹក្សាជាតិនៃគណបក្ស ឬគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត បង្កើតគណៈកម្មាធិការបណ្តោះអាសន្នមួយរបស់គណបក្ស តាមសំឡេងភាគច្រើនដាច់ខាត (៥០%+១)។

គណៈកម្មាធិការបណ្តោះអាសន្ន មានសមាជិកយ៉ាងតិចប្រាំពីររូប ដឹកនាំដោយប្រធានមួយរូប ដែលហៅថា ប្រធានគណបក្សបណ្តោះអាសន្ន។

ប្រធានគណបក្សបណ្តោះអាសន្ន ជ្រើសរើសដោយសមាជិកគណៈកម្មាធិការបណ្តោះអាសន្ន តាមសំឡេងភាគច្រើនដាច់ខាត (៥០%+១)។

ប្រការ៥៥(ថ្មី) ប្រការ៥៦(ថ្មី) ប្រការ៥៧(ថ្មី) និងប្រការ៥៨(ថ្មី) ក្នុងជំពូកទី៩ នៃលក្ខន្តិកៈនេះ អនុវត្ត សម្រាប់ការផ្តួចផ្តើមបង្កើតគណបក្ស និងអាចអនុវត្តដូចមានចែងក្នុងប្រការ២៩(ថ្មី) និងប្រការ៤៧(ថ្មី) នៃលក្ខន្តិកៈនេះ។

**ប្រការ ៥៦ (ថ្មី) ៖**

រាល់សេចក្តីសម្រេចរបស់គណៈកម្មាធិការបណ្តោះអាសន្ន គឺតាមសំឡេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកទាំងមូល។

គណៈកម្មាធិការបណ្តោះអាសន្ន មានភារកិច្ច ៖

- រៀបចំឯកសារនានា សម្រាប់ចុះបញ្ជី ឬពាក់ព័ន្ធនីតិវិធីរបស់គណបក្សជូនក្រសួងមហាផ្ទៃ
- រៀបចំ ដឹកនាំ និងសម្រេចរាល់កិច្ចការរបស់គណបក្ស រហូតដល់សមាជរបស់គណបក្សបានជោគជ័យ
- អនុម័ត លើលក្ខន្តិកៈគណបក្ស មុនដាក់ជូនសមាជរបស់គណបក្ស
- តែងតាំងក្រុមការងារ ឬគណៈកម្មាធិការនានា ដើម្បីដំណើរការគណបក្ស និងរៀបចំសមាជរបស់គណបក្ស
- រៀបបញ្ជី សមាជិកក្រុមប្រឹក្សាជាតិ សមាជិកគណៈកម្មាធិការនាយក ស្របតាមលក្ខន្តិកៈ ដើម្បីដាក់ជូនសមាជរបស់គណបក្ស ផ្តល់សេចក្តីទុកចិត្ត តាមសំឡេងភាគច្រើនដាច់ខាត (៥០%+១)
- កំណត់ចំនួនប្រតិភូតំណាងរបស់គណបក្ស ដែលជាអ្នកមានសិទ្ធិចូលរួម និងអនុម័តផ្តល់សេចក្តីទុកចិត្តក្នុងសមាជ។

**ប្រការ ៥៧ (ថ្មី) ៖**

គណៈកម្មាធិការបណ្តោះអាសន្នរបស់គណបក្ស ត្រូវរំសាយជាស្វ័យប្រវត្តិ នៅពេលសមាជរបស់គណបក្សទទួលបានជោគជ័យ ស្របតាមខ្លឹមសារនៃនីតិវិធីច្បាប់ ឬមានសុពលភាព។

**ប្រការ ៥៨ - ថ្មី៖**

តាមសំណើរបស់ប្រធានគណបក្ស ឬ១/៤នៃសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ឬ១/៤នៃគណៈកម្មាធិការនាយក ដើម្បីបំពេញការងារតាមតម្រូវការចាំបាច់មុនពេល ឬចន្លោះសមាជ គណៈកម្មាធិការនាយកសម្រេចដោយសំឡេងភាគច្រើនដាច់ខាត (៥០%+១)ក្នុងការជាកតួនាទី ឬជ្រើសតាំងបន្ថែម ៖

- សមាជិកក្រុមប្រឹក្សាជាតិ
- សមាជិកគណៈកម្មាធិការនាយក
- សមាជិកគណៈកម្មាធិការវិន័យ
- សមាជិកគណៈកម្មាធិការប្រតិបត្តិ
- សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍

## ជំពូកទី១០

## អវសានប្បញ្ញត្តិ

**ប្រការ ៥៩ ៖**

បទប្បញ្ញត្តិ ទាំងឡាយណាដែលផ្ទុយនឹងលក្ខន្តិកៈនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៦០ ៖**

លក្ខន្តិកៈនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាដោយប្រធានគណបក្ស។

ថ្ងៃអាទិត្យ ៦កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៥

**ប្រធានគណបក្ស**

**យ៉េម បុញ្ញឫទ្ធិ**

**បានតម្កល់ទុកលក្ខន្តិកៈ**

របស់

**គណបក្សប្រជាធិបតេយ្យជឿនលឿន**

ដែលបានចុះបញ្ជីតាមប្រកាសលេខ...១៣០៨០.....ប្រក
ចុះថ្ងៃទី...១៣......ខែ..វិច្ឆិកា...ឆ្នាំ២០២៥ របស់ក្រសួងមហាផ្ទៃ។
ថ្ងៃ..ព្រហស្បតិ៍...៨រោច..ខែ..កត្តិក..ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី..១៣..ខែ...វិច្ឆិកា...ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អគ្គបណ្ឌិតសភាចារ្យ ស សុខា**

# ឧបសម្ព័ន្ធទី១
# អត្ថន័យនៃរូបសញ្ញា

គណបក្សប្រជាធិបតេយ្យជឿនលឿន មានសញ្ញាសម្គាល់ រូបពន្លឺភ្លើងមានកាំរស្មីលើជើងទម្រ នៅចំកណ្តាល ចតុកោណស្មើពណ៌ខៀវ ៖

- ពណ៌ខៀវ តំណាងឱ្យភាពជឿជាក់ សន្តិភាព និងការអភិវឌ្ឍន៍។
- ពន្លឺភ្លើងមានកាំរស្មី តំណាងឱ្យពន្លឺសេរីភាព ប្រជាធិបតេយ្យ និងសេចក្តីសង្ឃឹម
- គណបក្សប្រជាធិបតេយ្យជឿនលឿន បង្ហាញពីការលើកកម្ពស់ប្រជាធិបតេយ្យ និងភាពរីកចម្រើន ល្អប្រសើរទៅតាមសម័យកាល។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណបក្សប្រជាធិបតេយ្យជឿនលឿន
DEMOCRATIC PROGRESSIVE PARTY
នីតិរដ្ឋ ភាតរភាព វឌ្ឍនភាព
លេខ៖ ..............................ប.ជ.ល

# រចនាសម្ព័ន្ធដឹកនាំ
# គណបក្សប្រជាធិបតេយ្យជឿនលឿន




ទីស្នាក់ការកណ្ដាល ៖ បុរីពិភពថ្មីកួរស្រូវ២ ផ្ទះលេខ៣៦ ផ្លូវលេខ៣៣ ភូមិក្រាំងស្វាយ សង្កាត់ព្រែកកំពឹស ខណ្ឌដង្កោ រាជធានីភ្នំពេញ
PiphupThmey KuorSrov2, #36 Street 33 - Phum Krang Svay - Sangkat Preaek Kampues - Khan Dangkao - Phnom Penh
Tel./Telegram : +855 17 952 954 / +855 98 200 008 / +855 70 687 887

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខៈ ១៣០៤០ ប្រក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាស
## ស្ដីពី
## ការប្ដូរឈ្មោះគណបក្សកម្ពុជានិយម
## មកជាឈ្មោះគណបក្សប្រជាធិបតេយ្យជឿនលឿន

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគណបក្សនយោបាយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៧/០០៣ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីគណបក្សនយោបាយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៧ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីគណបក្សនយោបាយ និងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីគណបក្សនយោបាយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០១ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា៤៥ថ្មី(ស្ទួន) នៃច្បាប់ស្ដីពីគណបក្សនយោបាយ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់គណបក្សកម្ពុជានិយម

# សម្រេច

**ប្រការ១ .-**

ត្រូវបានប្តូរឈ្មោះ គណបក្សកម្ពុជានិយម មកជាឈ្មោះ **គណបក្សប្រជាធិបតេយ្យជឿនលឿន** ក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ដោយមានអាសយដ្ឋានទីស្នាក់ការកណ្តាលនៅបុរីពិភពថ្មីក្បាលស្រូវ២ ផ្ទះលេខ៣៦ ផ្លូវលេខ៣៣ ភូមិក្រាំងស្វាយ សង្កាត់ព្រែកកំពឹស ខណ្ឌដង្កោ រាជធានីភ្នំពេញ។

**ប្រការ២ .-**

**គណបក្សប្រជាធិបតេយ្យជឿនលឿន** ត្រូវធ្វើសកម្មភាព និងបំពេញកាតព្វកិច្ចស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងលក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ។

**ប្រការ៣ .-**

ប្រកាសលេខ៣០២៨ ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ប្រធានអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ប្រធាននាយកដ្ឋានកិច្ចការសមាគមនិងគណបក្សនយោបាយ និងសាមីគណបក្ស ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...ព្រហស្បតិ៍ ៨ រោច...ខែ...កត្តិក... ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...១៣.... ខែ....វិច្ឆិកា..... ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- តុលាការកំពូល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ដូចប្រការ ៤ (ដើម្បីអនុវត្ត)
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ